# ឯកឧត្តម ចម ប្រសិទ្ធ ជួបអគ្គលេខាធិការអង្គការស្តង់ដារអន្តរជាតិ **(ISO)**



នៅរសៀលថ្ងៃទី ១១ ខែ មីនា ឆ្នាំ២០១៦ ឯកឧត្តម ចម ប្រសិទ្ធ ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម បានទទួលជួបលោក **Kevin Mckenlly** អគ្គលេខាធិការ អង្គការស្តង់ដារអន្តរជាតិ (ISO) ដើម្បីពិភាក្សាការងារនៅទីស្តីការក្រសួង ។

ក្នុងជំនួបនាឱកាសនោះ ឯកឧត្តម ទេសរដ្ឋមន្ត្រី ចម ប្រសិទ្ធ បានសម្តែងការស្វាគមន៍ និងថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅដល់អង្គការស្តង់ដារអន្តរជាតិ ISO ដែលកន្លងមក ក៏ដូចជាបច្ចុប្បន្ន បានសហការដ៏ល្អជាមួយអង្គភាពជំនាញកម្ពុជា ទាក់ទងនិងការពង្រឹងកិច្ចសហប្រតិបត្តិការលើវិស័យ ស្តង់ដារ និងការផ្តល់ជំនួយបច្ចេកទេសជាដើម ។ ឯកឧត្តម ទេសរដ្ឋមន្ត្រី បានជម្រាបថា៖ក្រសួងឧស្សាហកម្ម និងសិប្បកម្ម មានវិទ្យាស្ថានដ្ឋានស្តង់ដារកម្ពុជា ដែលមានឯកទេសក្នុងការវាយតម្លៃ និងផ្តល់វិញ្ញាបនបត្របញ្ជាក់គុណភាព និងស្តង់ដារផលិតផល ។ ប៉ុន្តែសមត្ថភាពនៅមានកំរិត ទាំងផ្នែកធនធានមនុស្ស និងឧបករណ៍ពិសោធន៍ ។ ដូច្នេះឯកឧត្តមទេសរដ្ឋមន្ត្រីស្នើឱ្យអង្គការ ISO ពិនិត្យលទ្ធភាពនិងចាត់ទុកជាអាទិភាពលើការងារនេះ ។ ឱកាសនោះដែរ ឯកឧត្តមទេសរដ្ឋមន្ត្រី បានស្នើឱ្យអង្គការ ISO ជួយអភិវឌ្ឍន៍ការងារស្តង់ដារក្នុងវិស័យឧស្សាហកម្មនៅកម្ពុជា ដែលកំពុងមានការរីកលូតលាស់គួរកត់សំគាល់នាពេលបច្ចុប្បន្ននេះ ពីព្រោះថា៖ក្រុមហ៊ុនរោងចក្រមានការរីកចម្រើនកាន់តែធំទៅៗដោយមានស្តង់ដារត្រឹមត្រូវ ។ ក្នុងនោះ ឯកឧត្តម ទេសរដ្ឋមន្ត្រី ចម ប្រសិទ្ធ ក៏បានជម្រាបជូនពីការយកចិត្តទុកដាក់របស់កម្ពុជា ដែលបានអនុម័តយកស្តង់ដារម្ហូបអាហារ នៅក្នុងអង្គការ CODEX

អន្តរជាតិ ជាង៣០០ស្តង់ដារ មកធ្វើជាស្តង់ដារជាតិ ដើម្បីជម្រុញ និងលើកកំពស់ វិស័យឧស្សាហកម្ម និងសិប្បកម្ម ក៏ដូចជាសហគ្រាសខ្នាតតូច និងមធ្យមក្នុងស្រុក ។



លោក **Kevin Mckenlly** អគ្គលេខាធិការអង្គការស្តង់ដារអន្តរជាតិ ISO បានវាយតម្លៃខ្ពស់ចំពោះកិច្ចសហការដ៏ល្អរវាងអង្គការ ISO ជាមួយក្រសួង ជាពិសេសជាមួយវិទ្យាស្ថានស្តង់ដារកម្ពុជា និងត្រៀមខ្លួនសហការជួយបន្តទៀតតាមលទ្ធភាពជាក់ស្តែង ដោយបានស្នើឱ្យក្រសួងដាក់សំណើរដែលចាត់ទុកជាគម្រោងអាទិភាពរបស់ខ្លួនមកអង្គការ ISO ដើម្បីពិនិត្យពិចារណា និងសម្រេច ។ ស្របពេលនោះដៃគូរសន្ទនាទាំងពីរ បានផ្តល់សារៈសំខាន់ទៅលើ ស្តង់ដារសុវត្ថិភាពចំណីអាហារ និងស្តង់ដារផលិតផលនេសាទ ពីព្រោះវាទាក់ទង និងឧត្តមភាពប្រកួតប្រជែង សមត្ថភាពការកែឆ្នៃ និងពាណិជ្ជកម្មអន្តរជាតិ ។ ក្នុងនោះ ការផ្តល់ជំនួយបច្ចេកទេស ការបណ្តុះបណ្តាលធនធានមនុស្ស និងពង្រឹងស្ថាប័នដល់កម្ពុជា ត្រូវបានចាត់ទុកជាការងារអាទិភាព ដែលត្រូវពង្រឹងកិច្ចសហប្រតិបត្តិការបន្ថែម ។

